# ប្រកាសព័ត៌មាន លេខ ៤៦ (ប្រចាំខែ មករា ២០១៨)

សម្រាប់ខែមករាឆ្នាំ២០១៨ នេះ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ នៅក្រសួងចំនួន ១០ និងប្រកាសបន្តអនុវត្តគម្រោង FMIS ដំណាក់កាលទី២ ទៅកាន់ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៨។

### ❖ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ

ក្រុមការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធ FMIS បានសម្រេចជោគជ័យក្នុងការតភ្ជាប់បណ្ដាញពីមជ្ឈមណ្ឌលទិន្នន័យទៅកាន់ក្រសួង-ស្ថាប័នទាំង១០ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធចំនួន១០ និងបានដំឡើងកុំព្យូទ័រ និងសម្ភារបច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់បប្រព័ន្ធ FMIS ប្រមាណជាង ២៧៥រូប។ ក្រៅពីនេះក្រុមការងារនៅតែបន្តការត្រួតពិនិត្យ ជួសជុល និងថែទាំឧបករណ៍បច្ចេកវិទ្យាព័ត៌មានសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធ។

### ❖ ការគ្រប់គ្រងមុខងារប្រព័ន្ធ

ក្រុមការងារមុខងារប្រព័ន្ធ រួមជាមួយក្រុមការងារគ្រប់គ្រងការផ្លាស់ប្ដូរ បានសហការក្នុងការចុះគាំទ្រដោយផ្ទាល់ និងបង្ហាត់បង្ហាញបន្ថែមដល់ទីតាំងអ្នកប្រើប្រាស់ប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័នទាំង ១០ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ដើម្បីទ្រទ្រង់ដល់ការប្រើប្រាស់លើប្រព័ន្ធ FMIS។ ការចុះគាំទ្រនេះធ្វើឡើងបន្ទាប់ពីការបញ្ចប់វគ្គបណ្ដុះបណ្ដាលទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងគោលបំណងជួយសម្របសម្រួលឱ្យអ្នកប្រើប្រាស់ប្រព័ន្ធ FMIS អាចអនុវត្តប្រព័ន្ធ FMIS នេះប្រកបដោយភាពរលូន។

### ❖ ការគ្រប់គ្រងការផ្លាស់ប្ដូរ

ក្រុមការងារគ្រប់គ្រងការផ្លាស់ប្ដូរបានជួយរៀបចំ និងសម្របសម្រួល ក្នុងការរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការក្នុងឆ្នាំ២០១៨ និងបានធ្វើបច្ចុប្បន្នភាពជាប្រចាំលើគេហទំព័រ និងបណ្ដាញសង្គមរបស់ FMIS និងបានផ្សព្វផ្សាយផ្ទាំងព័ត៌មាន (Posters) នានាពាក់ព័ន្ធនឹងសកម្មភាពនៃការអនុវត្តគម្រោង FMIS និង វឌ្ឍនភាពនៃគម្រោង FMIS។ បានបោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានលេខ ១៣ ចែកជូនតាមអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម÷

*http://fmis.mef.gov.kh* *fmis.info@mef.gov.kh* *023 430 063*

FMIS CAMBODIA FMIS CAMBODIA